S4-P4

ADB

## Strategic Program for Climate Resilience

*Mainstreaming Climate Resilience into Development Planning (TA 8179)*

***(September 2013-April 2019)***



# ការអនុវត្តការបន្ស៊ាំការប្រែប្រួលអាកាសធាតុ ដោយជនជាតិភាគតិច ឬជាលក្ខណៈប្រពៃណីក្នុងផ្នែកកសិកម្ម

**ឈ្មោះ៖ ឡាយ ចន្ធី**

អ្នកឯកទេសបន្ស៊ាំការប្រែប្រួលអាកាសធាតុ

ក្រុងព្រះសីហនុ ថ្ងៃទី ៣០ វិច្ឆិកា ២០១៦

CLIMATE INVESTMENT FUNDS

icem

# ករណីសិក្សាការអនុវត្តន៍ការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ជនជាតិភាគតិច ឬជាលក្ខណៈប្រពៃណី

- ជាករណីការអនុវត្តជាក់ស្តែងលើការបន្សាំរបស់ជនជាតិភាគតិច ឬជាលក្ខណៈប្រពៃណី ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ករណីការអនុវត្តជាក់ស្តែងលើការបន្សាំរបស់ជនជាតិភាគតិច ឬជាលក្ខណៈប្រពៃណី ក្នុងផ្នែកកសិកម្ម ដែលបានប្រមូល និងចងក្រង
  - **សហគមន៍ការពារព្រៃឈើតាមបែបចូលរួមក្នុងខេត្តមណ្ឌលគិរី**
  - សហគមន៍កសិករប្រើប្រាស់ទឹកក្នុងខេត្តមណ្ឌលគិរី
  - ការដាំដុះនៅតំបន់ខ្ពង់រាប និងការធ្វើដំណាំចន្លោះព្រៃក្នុងខេត្តមណ្ឌលគិរី
  - ការដាំដុះដោយប្រើពូជស្រូវក្នុងស្រុក ក្នុងឃុំជីខលើ ខេត្តកោះកុង
  - ការបន្សាំក្នុងការលើកកម្ពស់ការចិញ្ចឹមត្រីបែតង ក្នុងសហគមន៍តំបន់មាត់សមុទ្រ ក្នុងខេត្តកោះកុង

# ករណីសិក្សាពីសហគមន៍ការពារព្រៃឈើតាមបែបចូលរួម ក្នុងខេត្តមណ្ឌលគិរី

## ព័ត៌មានសំខាន់ពីករណីសិក្សា

- **ប្រធានបទ:** ការអនុវត្តន៍ការបន្សាំការប្រែប្រួលអាកាសធាតុរបស់សហគមន៍ការពារព្រៃឈើស្រែអ៊ី
- **ទីតាំង៖** សហគមន៍ការពារព្រៃឈើស្រែអ៊ី ឃុំស្រែអ៊ី ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី
- **ភូមិសាស្ត្រ៖** តំបន់ភ្នំ និងខ្ពង់រាប, តំបន់ព្រៃការពារ,
- **ការប្រែប្រួលអាកាសធាតុ៖** រាំងស្ងួត, ការកើនសីតុណ្ហភាព

# សហគមន៍ការពារព្រៃឈើស្រែអ៊ី

- **មនុស្ស៖** ជាពលរដ្ឋភាគច្រើនគឺជនជាតិភាគតិចព្នង
- **ជីវភាពរស់នៅ៖** កសិកម្មវិលជុំ ទាញអនុផលព្រៃឈើ បំរើពលកម្មលើការដាំដុះ និងអេកូទេសចរណ៍
- **បញ្ហាជួបប្រទះ៖** ការរិចរិលធនធានព្រៃឈើ, ការកាប់បំផ្លាញព្រៃឈើ, ការប្រែប្រួលអាកាសធាតុ (ប្រែប្រួលកម្រិតភ្លៀងធ្លាក់ កើនសីតុណ្ហភាព), និងការខ្វះខាតទឹកប្រើប្រាស់
- **បញ្ហាដោះស្រាយ៖** ត្រូវការចាំបាច់ជម្រើសប្រភពចំណូល និងការដោះស្រាយបញ្ហាខ្វះទឹកប្រើប្រាស់។



# សហគមន៍ការពារព្រៃឈើស្រែអ៊ី

- **ដីប្រើប្រាស់របស់សហគមន៍៖** (i) ដីព្រៃអារក្ស (ii) ដីកប់ខ្មោច (iii) ដីកសិកម្ម (iv) ដីលំនៅដ្ឋាន (v) ដីព្រៃបម្រុងទុក
- ការវិវឌ្ឍន៍របស់សហគមន៍
  - ឆ្នាំ 1996 ដីព្រៃទាំងអស់ក្នុងឃុំស្រែអ៊ី ត្រូវបានដាក់ជាតំបន់ការពារ
  - ឆ្នាំ 2009 បានបង្កើតជាសហគមន៍មូលដ្ឋានតំបន់ការពារស្រែអ៊ី
  - ឆ្នាំ 2012 មន្ទីរបរិស្ថានខេត្តបានទទួលស្គាល់សហគមន៍
  - ឆ្នាំ 2014 គម្រោងការអភិរក្សជីវចម្រុះនៅតំបន់ច្រករបៀង (BCC) បានផ្តល់ការគាំទ្រដល់សហគមន៍ក្នុងការការពារព្រៃឈើ និងជីវចម្រុះរបស់វា។
    - បង្កើនការរក្សាទឹកទុកប្រើប្រាស់ និងកែលម្អផ្នែកអនាម័យ
    - កែលម្អព្រៃឈើតាមរយៈការការពារព្រៃឈើ និងដាំកូនឈើដាំឡើងវិញ
    - ការបង្កើតផ្លូវភ្លើង

# សហគមន៍ការពារព្រៃឈើស្រែអ៊ី





# វិធានការបន្សាំការប្រែប្រួលអាកាសធាតុរបស់សហគមន៍

- សហគមន៍គ្រប់គ្រងព្រៃឈើ គឺជួយរក្សាភាពលំនឹងនៃបរិស្ថានព្រៃឈើ កាត់បន្ថយការហូរច្រោះ និងបង្កើនលទ្ធភាពក្នុងការប្រមូលអនុផលព្រៃឈើ និងបង្កើនប្រាក់ចំណូល
- ការបង្កើតផ្លូវភ្លើង សម្រាប់ការពារភ្លើងឆេះព្រៃនៅរដូវរាំងស្ងួត
- **កសិកម្ម :** ការផ្លាស់ប្តូរពីដំណាំស្រូវដែលផ្តល់ទិន្នផលតិច និងប្រើទឹកច្រើនក្នុងការដាំដុះ មកដាំដុះដំណាំដំឡូងមីជំនួសវិញ ដែលប្រើទឹកតិច និងបានចំណូលច្រើនជាង
- បង្កើនការពារក្សាទឹកទុកប្រើប្រាស់ ការការពារច្រប់ ការប្រមូលទឹកភ្លៀងទុកប្រើប្រាស់ និងកែលម្អផ្នែកអនាម័យ
- កែលម្អព្រៃឈើតាមរយៈការការពារព្រៃឈើ និងដាំកូនឈើដាំឡើងវិញ (គម្រោងBCC បានផ្តល់កូនឈើដល់សហគមន៍ចំនួន ៥៥០០ ដើមក្នុងមួយឆ្នាំ) ។

# វិធានការបន្សាំការប្រែប្រួលអាកាសធាតុរបស់សហគមន៍





# វិធានការបន្សាំការប្រែប្រួលអាកាសធាតុ របស់សហគមន៍





# ផលប្រយោជន៍ពីការអនុវត្តន៍

- សហគមន៍បានរក្សា និងបង្កើនជីវភាពរស់នៅដោយការបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈ៖
  - ការការពារព្រៃ ការបង្កើនអនុផលព្រៃឈើ
  - ការផ្លាស់ប្តូរមុខដំណាំ ដែលផ្តល់ផលច្រើន និងត្រូវការទឹកតិច
  - ការការពារទឹក ការពារច្រប់ ការប្រមូលទឹកភ្លៀងទុកប្រើប្រាស់
- ផ្តល់ជាសក្តានុពលក្នុងទាក់ទាញទេសចរណ៍ និងការជម្រុញផ្នែកអេកូទេសចរណ៍
- សហគមន៍ការពារព្រៃឈើស្រែអ៊ី អាចបង្កើនចំណូលប្រចាំគ្រួសារ និងចូលរួមចំណែកក្នុងការរក្សាសន្តិសុខស្បៀង និងជីវភាពរស់នៅក្នុងតំបន់។

# ការប្រុងប្រយ័ត្នពីការអនុវត្តន៍របស់សហគមន៍

- **សហគមន៍ព្រៃឈើ អេកូទេសចរណ៍ និងការប្រមូលអនុផលព្រៃឈើ**
  - មិនមែនរាល់សហគមន៍ការពារព្រៃឈើទាំងអស់ សុទ្ធតឹសមស្របលក្នុងប្រែក្លាយទៅជាតំបន់អេកូទេសចរណ៍នោះទេ។
  - ករណីឃុំស្រែអ៊ី គឺត្រូវការការសិក្សាបន្ថែម ដើម្បីស្វែងរកវិធីសាស្ត្រក្នុងការគ្រប់គ្រងការប្រមូលអនុផលព្រៃឈើប្រកបដោយប្រសិទ្ធិភាព
- **យោបល់** – គម្រោង BCC
  - ការផ្តល់កូនឈើចំនួន 5,500 ដើម ក្នុងមួយឆ្នាំ គឺជាចំនួនតិចនៅឡើយ អត្រាស្តារឡើងវិញគឺបានតែពី 60-70% ប៉ុណ្ណោះ គួរបង្កើនចំនួន
  - ជួយបង្កើនសមត្ថភាពសហគមន៍បន្ថែមក្នុងការទាញទឹកភ្លៀងទុកប្រើប្រាស់ តាមរយៈការបង្កើនចំនួនពាងស្តុកទឹកទុក

# សូមអរគុណ !



www.spcrcambodia.org

ADB CLIMATE INVESTMENT FUNDS icem